ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១០-០០១ សរ.ណន

# សារាចរណែនាំ
# ស្តីពី
# ការកំណត់ចំណាត់ថ្នាក់វិនិយោគ

ដើម្បីអនុវត្តច្បាប់ ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខនស/រកម/ ១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និងប្រកាសលេខ ធ៧-០៨-១៩៣ ប្រក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជី និងលក្ខខណ្ឌសុំអាជ្ញាបណ្ណចំពោះគ្រឹះស្ថានធនាគារឲ្យមានភាពរលូនស្របតាមការវិវត្តនៃប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាណែនាំអំពីចំណាត់ថ្នាក់វិនិយោគសម្រាប់ភាគទុនិកមានឥទ្ធិពលដែលជាគ្រឹះស្ថានធនាគារ ឬជាគ្រឹះស្ថានហិរញ្ញវត្ថុ និងកាតព្វកិច្ចពាក់ព័ន្ធនានារបស់គ្រឹះស្ថានធនាគារ ដែលទទួលបានអាជ្ញាបណ្ណប្រកបមុខរបរធនាគារនៅព្រះរាជាណាចក្រកម្ពុជា ដូចតទៅ ៖

១- ភាគទុនិកមានឥទ្ធិពលទាំងនេះត្រូវទទួលបានការវាយតម្លៃពីភ្នាក់ងារចាត់ថ្នាក់អន្តរជាតិ (International Rating Agencies) យ៉ាងតិចចំនួនមួយ ក្នុងចំណោមភ្នាក់ងារចាត់ថ្នាក់អន្តរជាតិបីគឺ Moody's Asia Pacific, Standard & Poor's Corporation និង Fitch ។ ចំណាត់ថ្នាក់វិនិយោគនេះសំដៅលើចំណាត់ថ្នាក់រយៈពេលវែង (Long Term Rating) ដែលស្ថិតក្នុងចំណាត់ថ្នាក់ណាមួយដូចខាងក្រោម ៖

| Moody's Asia Pacific | Standard & Poor's Corporation | Fitch | |
|---|---|---|---|
| **Long Term Rating** | **Long Term Rating** | **Long Term Rating** | |
| Aaa | AAA | AAA | Prime |
| Aa1 | $AA^{+}$ | $AA^{+}$ | High grade |
| Aa2 | AA | AA | |
| Aa3 | AA- | AA- | |
| A1 | $A^{+}$ | $A^{+}$ | Upper Medium grade |
| A2 | A | A | |
| A3 | A- | A- | |
| Baa1 | $BBB^{+}$ | $BBB^{+}$ | Lower Medium grade |
| Baa2 | BBB | BBB | |
| Baa3 | BBB- | BBB- | |

២- ធនាគារពាណិជ្ជ ដែលមានភាគទុនិកមានឥទ្ធិពលយ៉ាងតិចមួយជាគ្រឹះស្ថានធនាគារ ឬជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានការវាយតម្លៃ "ចំណាត់ថ្នាក់វិនិយោគ" ដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិត្រូវមានដើមទុនអប្បបរមាស្មើនឹង ៥០.០០០.០០០.០០០(ហាសិបពាន់លាន)រៀល។ ធនាគារពាណិជ្ជដែលពុំមានភាគទុនិកមានឥទ្ធិពល

ជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានចំណាត់ថ្នាក់វិនិយោគ ត្រូវមានដើមទុនអប្បបរមាស្មើនឹង ១៥០.០០០.០០០.០០០ (មួយរយហាសិបពាន់លាន) រៀល។ ធនាគារពាណិជ្ជដែលបង្កើតបុត្រសម្ព័ន្ធ ត្រូវមានដើមទុនអប្បបរមាចំនួន ១៥០.០០០.០០០.០០០ (មួយរយហាសិបពាន់លាន) រៀល ទោះបីជាក្រុមហ៊ុនមេនៅបរទេស ឬភាគទុនិកដែលមានឥទ្ធិពលមានចំណាត់ថ្នាក់វិនិយោគក៏ដោយ។

៣- ធនាគារឯកទេស ដែលមានភាគទុនិកមានឥទ្ធិពលយ៉ាងតិចមួយជាគ្រឹះស្ថានធនាគារ ឬជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានការវាយតម្លៃ "ចំណាត់ថ្នាក់វិនិយោគ" ដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិត្រូវមានដើមទុនអប្បបរមាស្មើនឹង ១០.០០០.០០០.០០០(ដប់ពាន់លាន) រៀល។ ធនាគារឯកទេសដែលពុំមានភាគទុនិកមានឥទ្ធិពលជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានចំណាត់ថ្នាក់វិនិយោគ ត្រូវមានដើមទុនអប្បបរមាស្មើនឹង ៣០.០០០.០០០.០០០ (សាមសិបពាន់លាន) រៀល។ ធនាគារឯកទេសដែលបង្កើតបុត្រសម្ព័ន្ធ ត្រូវមានដើមទុនអប្បបរមាចំនួន ៣០.០០០.០០០.០០០ (សាមសិបពាន់លាន) រៀល ទោះបីជាក្រុមហ៊ុនមេនៅបរទេស ឬភាគទុនិកដែលមានឥទ្ធិពលមានចំណាត់ថ្នាក់វិនិយោគក៏ដោយ។

៤- គ្រឹះស្ថានធនាគារត្រូវផ្តល់លិខិតបញ្ជាក់អំពីចំណាត់ថ្នាក់វិនិយោគ (Confirmation of the Rating) របស់ភាគទុនិកមានឥទ្ធិពលរបស់ខ្លួនដែលចេញដោយភ្នាក់ងារចាត់ថ្នាក់អន្តរជាតិមួយក្នុងចំណោមភ្នាក់ងារចាត់ថ្នាក់អន្តរជាតិទាំងបីខាងលើ មកធនាគារជាតិនៃកម្ពុជាឲ្យបានទៀងទាត់រៀងរាល់ដើមឆមាសនីមួយៗ។ លើសពីនេះទៀតគ្រឹះស្ថានធនាគារត្រូវរាយការណ៍ជាបន្ទាន់មកធនាគារជាតិនៃកម្ពុជា ប្រសិនបើភ្នាក់ងារវាយតម្លៃបន្ថយការធ្វើចំណាត់ថ្នាក់ភាគទុនិកដែលមានឥទ្ធិពលទៅក្រោមចំណាត់ថ្នាក់វិនិយោគ។

៥- ភាគទុនិកមានឥទ្ធិពលត្រូវចេញលិខិតធានាបង្កើនដើមទុន នៅពេលចំណាត់ថ្នាក់របស់ខ្លួនធ្លាក់ក្រោមចំណាត់ថ្នាក់វិនិយោគ ឬនៅពេលដែលធនាគារជាតិនៃកម្ពុជាតម្រូវឲ្យបង្កើនដើមទុនដោយផ្អែកលើការវាយតម្លៃអំពីស្ថានភាពហានិភ័យរបស់ធនាគារ។ លិខិតធានាបង្កើនដើមទុននេះត្រូវមានចែងពីការសន្យាដែលមិនអាចកែប្រែបាន (Irrevocable) ចំពោះធនាគារជាតិនៃកម្ពុជា ក្នុងការផ្តល់ដើមទុនបន្ថែមនៅក្នុងរវាង ៥ (ប្រាំ)ថ្ងៃធ្វើការ និងបញ្ចប់ការរៀបចំសំណុំឯកសារបង្កើនដើមទុននៅក្នុងរវាង ៣០ថ្ងៃ ចាប់ពីថ្ងៃផ្ទេរដើមទុន។ លិខិតធានាបង្កើនដើមទុនត្រូវភ្ជាប់មកជាមួយនូវសេចក្តីសម្រេចបង្កើនដើមទុនរបស់ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនមេ ឬធនាគារមេដែលជាភាគទុនិកមានឥទ្ធិពល និងត្រូវបានជូនដំណឹងទៅអាជ្ញាធរត្រួតពិនិត្យប្រទេសដើម។

៦- ការសន្យាផ្តល់លិខិតបញ្ជាក់ ការសន្យារាយការណ៍ និងលិខិតធានាបង្កើនដើមទុន ដូចមាននៅក្នុងចំណុច ៤ និង៥ខាងលើត្រូវមានចែងនៅក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីភាគទុនិកមានឥទ្ធិពល។ ឯកសារដែលនឹងផ្តល់ជូនធនាគារជាតិនៃកម្ពុជារួមមាន៖

- ច្បាប់ចម្លងនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល (ការសន្យាផ្តល់លិខិតបញ្ជាក់ ការសន្យារាយការណ៍ និងលិខិតធានាបង្កើនដើមទុន)
- លិខិតជូនដំណឹងទៅអាជ្ញាធរត្រួតពិនិត្យប្រទេសដើមអំពីការតម្រូវរបស់ធនាគារជាតិនៃកម្ពុជាឲ្យមានការសន្យាផ្តល់លិខិតបញ្ជាក់ ការសន្យារាយការណ៍ និងលិខិតធានាបង្កើនដើមទុន និង
- លិខិតធានាបង្កើនដើមទុនរបស់ភាគទុនិកមានឥទ្ធិពល។

៧- ក្នុងករណីដែលគ្រឹះស្ថានធនាគារស្វែងរកជំនួយគាំទ្រពីធនាគារបរទេស គ្រឹះស្ថានធនាគារនោះត្រូវផ្តល់ព័ត៌មានដូចខាងក្រោមមកធនាគារជាតិនៃកម្ពុជាត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០៖

- អនុស្សារណៈយោគយល់ ឬលិខិតស្ម័គ្រចិត្តចូលរួមវិនិយោគដោយមិនអាចកែប្រែបានដោយមានបញ្ជាក់ពីចំនួនភាគហ៊ុនដែលមានបំណងកាន់កាប់ និងផែនការយុទ្ធសាស្ត្រ ស្តីពីការវិនិយោគនៅកម្ពុជាដែលឆ្លុះបញ្ចាំងនូវការប្តេជ្ញារយៈពេលវែង និងពីចំណាប់អារម្មណ៍ក្នុងការធ្វើប្រតិបត្តិការនៅកម្ពុជា ។
- ច្បាប់ចម្លងស្តីពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលធនាគារបរទេស និងលិខិតជូនដំណឹងដល់អាជ្ញាធរត្រួតពិនិត្យប្រទេសដើម អំពីគោលបំណងវិនិយោគរបស់ធនាគារបរទេសនោះ ។
- សេចក្តីប្រកាសរបស់ធនាគារបរទេសអំពីការយល់ដឹងនូវការទទួលខុសត្រូវរបស់ខ្លួនជាភាគទុនិកមានឥទ្ធិពលស្របតាមច្បាប់ និងបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ហើយសន្យាអនុវត្តតាមឲ្យបានពេញលេញ។

សារាចរណែនាំនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១០

**ទេសាភិបាល**

ជា_ចាន់តូ

**ចម្លងជូន**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"
- ឯកសារកាលប្បវត្តិ